# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីគាថាមួយបទនៅក្នុងធម្មបទនៃគម្ពីរព្រះពុទ្ធសា-សនាពោលថា បុគ្គលណាប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយការធ្វើសេចក្តីទុក្ខឲ្យកើតមានដល់អ្នកដទៃ បុគ្គលនោះតែងជាប់ជំពាក់ គឺពៀរវេរានិងមិនរួចផុតអំពីពៀរវេរាឡើយ

web site: hoksavann.org

ថ្ងៃទី២៩ ឧសភា ២០០៥

គាថាថា បុគ្គលណាប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយការធ្វើសេចក្តីឲ្យកើតមានដល់អ្នកដទៃ បុគ្គលនោះតែងជាប់ជំពាក់ដោយគ្រឿងជាប់ គឺពៀរ មិនមិនរួចផុតអំពីពៀរវេរានេះ ចេញពីបាលីថា បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ វេរសំសគ្គ សំសដ្ឋោ វេរា សោ ន បរិមុច្ចតិ ។ គាថានេះមានសេចក្តីថា មនុស្សគ្រប់រូបតែងតែប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ចង់រស់នៅប្រកបដោយសេចក្តីចំរើនរុងរឿងដូចគ្នា ។ ប៉ុន្តែមនុស្សខ្លះចង់បានសុខខ្លួនឯង បែរទៅជាបៀតបៀនអ្នកដទៃ ដែលជាហេតុនាំឲ្យមានទុក្ខដល់ខ្លួនទៅវិញ ។ គឺការប្រព្រឹត្តធ្វើអំពើអាក្រក់ ប៉ះពាល់ដល់សេចក្តីសុខរបស់អ្នកដទៃ ។ ព្រះពុទ្ធសំដែងថា មនុស្សកើតមកត្រូវបំពេញការងារ ប៉ុន្តែការងារដែលត្រឹមត្រូវ ការងារដែលមិនមានទោស ការងារដែលមិនធ្វើឲ្យអ្នកដទៃមានសេចក្តីទុក្ខព្រួយភ័យខ្លាច ឬធ្វើឲ្យគេវិនាស ប៉ុន្តែត្រូវបំពេញការងារប្រកបដោយសុចរិត ដែលហៅថាសម្មាអាជីវោ ប្រែថាការងារដ៏ប្រពៃ ។ ខាងចុងនៃគាថានេះបញ្ជាក់ថា បើបុគ្គលបៀតបៀនធ្វើឲ្យគេមានទុក្ខ បុគ្គលនោះតែងទទួលផលបាបធ្វើឲ្យខ្លួនមានទុក្ខវិញ តាមកម្រិតអកុសលដែលខ្លួនបានប្រព្រឹត្ត ។ ពាក្យថាពៀរ គឺផលនៃអំពើបាបនេះឯង ។ ប៉ុន្តែពៀរម៉្យាងទៀត សំដៅយកការចងកំហឹងនឹងគ្នាពីជាតិនេះរហូតដល់ជាតិខាងមុខទៀត ។

អំពើដែលធ្វើឲ្យគេមានទុក្ខមានប្រភេទច្រើនយ៉ាង មានបុគ្គលខ្លះក្នុងលោកនេះ ចង់បានទ្រព្យសម្បត្តិអ្នកដទៃ ក៏ប្រព្រឹត្តការលួចឆក់ប្លន់ បើអ្នករដ្ឋការប្រព្រឹត្តអំពើពុករលួយ មានអ្នកលួចឬប្លន់ខ្លះហ៊ានរហូតដល់សម្លាប់ម្ចាស់ទ្រព្យថែមទៀត ។ ធ្វើឲ្យគេមានទុក្ខ គឺធ្វើឲ្យគេអស់ទ្រព្យសម្បត្តិ ហើយមានម្ចាស់ទ្រព្យខ្លះត្រូវបាត់បង់ជីវិតថែមទៀត ។ ការលួចប្រពន្ធកូនអ្នកដទៃដើម្បីបំពេញតណ្ហារបស់ខ្លួន នេះជាការប៉ះពាល់ដល់សេចក្តីសុខអ្នកដទៃ ដែលគេចង់ជួបជុំប្តីប្រពន្ធកូនចៅមិនចង់បែកបាក់គ្នាដូចខ្លួនអ្នកប្រព្រឹត្តអាក្រក់នោះដែរ ។ បើអ្នកនយោបាយវិញ លួចសម្លាប់គ្នាដើម្បីបំពេញបំណងរបស់ខ្លួន ដែលធ្វើឲ្យគ្រួសារគេព្រាត់ប្រាស់គ្នា ហើយធ្វើឲ្យជាតិមានអសន្តិសុខផង ។ បើអ្នករដ្ឋការប្រព្រឹត្តអំពើពុករលួយស៊ីសំណូក ធ្វើឲ្យសេដ្ឋកិច្ចជាតិចុះទន់ខ្សោយ ធ្វើឲ្យប្រជាពលរដ្ឋមានភាពក្រីក្រ ។ បើក្នុងប្រទេសកើតសង្គ្រាមនិងគ្នាវិញ នឹងធ្វើឲ្យប្រជាពលរដ្ឋស្លាប់ព្រាត់ប្រាស់គ្នា ពិការបាក់ដៃបាក់ជើង នេះជាសេចក្តីទុក្ខដែលបង្កឡើងដោយបុគ្គលបាប ។

អ្នកកសាងបាបកម្មដោយការលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃឬរបស់ជាតិ បើគេចាប់បាននឹងទទួលទោសទណ្ឌកម្មក្នុងបច្ចុប្បន្ន បើគេចាប់ពុំបានទេ ក៏គេចពុំផុតអំពីទោសទៅមុខទៀតដែរ ។ ក្នុងសុត្តន្តបិដកនិយាយថា អ្នកដែលលួចទ្រព្យសម្បត្តិអ្នកដទៃ ស្លាប់ទៅធ្លាក់ទៅសោយទុក្ខក្នុងនរក លុះសេសសល់ផលកម្ម បើបានមកកើតជាមនុស្សវិញ បើមានទ្រព្យសម្បត្តិក៏ទុកពុំគង់ ចេះតែវិនាសទៅវិញដោយហេតុផ្សេងៗ ។ បើបុគ្គលសម្លាប់គេឬប្រើគេឲ្យសម្លាប់ បើគេចាប់បាននឹងមានទោសទណ្ឌកម្មក្នុងបច្ចុប្បន្នតាមច្បាប់របស់រដ្ឋ ។ លុះបុគ្គលនោះស្លាប់ទៅនឹងធ្លាក់ទៅសោយទុក្ខក្នុងនរក លុះសេសសល់ផលកម្ម បើបានកើតមកជាសត្វឬមនុស្ស ត្រូវគេសម្លាប់ជាច្រើនជាតិ មានអាយុខ្លីដោយទោសនៃការសម្លាប់គេពីជាតិមុន ។ ដូច្នេះតាមអត្ថន័យនៃពុទ្ធភាសិតខាងលើនេះបញ្ជាក់ថា បើបុគ្គលចង់បានសេចក្តីសុខដល់ខ្លួន មិនត្រូវបៀតបៀនមនុស្សសត្វដទៃឡើយ ផ្ទុយទៅវិញត្រូវសាងអំពើល្អ ព្រោះសេចក្តីសុខកើតពីការសាងអំពើល្អនេះឯង សមដូចពុទ្ធភាសិតមួយបទពោលថា នត្ថិ សន្តិ បរំ សុខំ មានន័យថា សេចក្តីសុខកើតពីការស្ងប់ គឺស្ងប់ពុំធ្វើបាបនេះឯង ៕